ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសុខាភិបាល

ថ្ងៃ ច័ន្ទ ៣ រោច ខែ ផល្គុន ឆ្នាំជូត ទោស័ក ព.ស ២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ មីនា ឆ្នាំ២០២១

# សេចក្តីជូនព័ត៌មានរបស់ក្រសួងសុខាភិបាល

ក្រសួងសុខាភិបាលសូមជម្រាបជូនសាធារណជនជ្រាបថា បច្ចុប្បន្ននេះក្រសួងសុខាភិបាលសង្កេតឃើញមានការផ្សព្វផ្សាយលក់ផលិតផលបំប៉នសុខភាព ឬអាហារបំប៉នសុខភាពដូចជា សារ៉ាយសមុទ្រSpirulina និងផលិតផលបំប៉នសុខភាព ឬអាហារបំប៉នសុខភាពដទៃទៀត នៅលើបណ្តាញសង្គមនានាយ៉ាងផុលផុស ដោយបានប្រើប្រាស់នូវខ្លឹមសារភូតកុហក បោកប្រាស់ ផ្ទុយពីគុណភាពរបស់ផលិតផលទាំងនោះ ធ្វើឱ្យប្រជាពលរដ្ឋមានការយល់ច្រឡំក្នុងការទិញផលិតផលបំប៉នសុខភាព ឬអាហារបំប៉នសុខភាពមកប្រើប្រាស់ សម្រាប់ព្យាបាលជំងឺ ដែលបណ្តាលឱ្យអូសបន្លាយពេលវេលាក្នុងការព្យាបាល បង្កឱ្យការព្យាបាលជំងឺមិនបានទាន់ពេលវេលា ធ្វើឲ្យអ្នកជំងឺកាន់តែធ្ងន់ធ្ងរទៅៗ ឬឈានដល់ការបាត់បង់អាយុជីវិត។

អាស្រ័យហេតុនេះ ក្រសួងសុខាភិបាលសូមជម្រាបជូនដល់បងប្អូនប្រជាពលរដ្ឋទាំងអស់ឱ្យបានជ្រាបថា៖ ផលិតផលបំប៉នសុខភាព ឬអាហារបំប៉នសុខភាព គ្រាន់តែមានមុខងារក្នុងការជួយទ្រទ្រង់សរីរាង្គកាយ និងជំនួយកំលាំងតែប៉ុណ្ណោះ តាមរយៈការបំពេញបន្ថែមកង្វះខាតនៃសារធាតុចាំបាច់ដែលសរីរាង្គកាយយើងត្រូវការ ដើម្បីបំពេញមុខងារសរីរាង្គ ប៉ុន្តែផលិតផលបំប៉នសុខភាព ឬអាហារបំប៉នសុខភាពមិនអាចជំនួសចំណីអាហារដែលយើងបរិភោគប្រចាំថ្ងៃបានទេ **និងគ្មានប្រសិទ្ធភាពក្នុងការធ្វើរោគវិនិច្ឆ័យ បង្ការ ឬព្យាបាលជំងឺ ដូចជាជំងឺមហារីក ជំងឺសន្លាក់ ជំងឺទឹកនោមផ្អែម លើសឈាម.........បានឡើយ ផ្ទុយទៅវិញផលិតផលបំប៉នសុខភាព ឬអាហារបំប៉នសុខភាពមួយចំនួនអាចបង្កឱ្យមានហានិភ័យចំពោះសុខភាព និងជួនកាលអាចបង្កគ្រោះថ្នាក់ដល់អាយុជីវិតផងដែរ។** ម្យ៉ាងទៀតក្រសួងសុខាភិបាលសូមរំលឹកថា ការប្រើប្រាស់ផលិតផលបំប៉នសុខភាព ឬអាហារបំប៉នសុខភាពមិនអាចជំនួសឱសថ ដែលបងប្អូនប្រជាពលរដ្ឋកំពុងប្រើប្រាស់ក្នុងការព្យាបាលជំងឺកុំរ៉ៃផ្សេងៗបានឡើយ។ ដូច្នេះមុននឹងសម្រេចចិត្តប្រើផលិតផលទាំងនេះ ត្រូវពិគ្រោះជាមួយគ្រូពេទ្យ ឬអ្នកដែលមានជំនាញសុខាភិបាលឱ្យបានច្បាស់លាស់ ដែលពួកគាត់អាចណែនាំយើងឱ្យដឹងពីតុល្យភាពរវាងចំណីអាហារត្រូវបរិភោគប្រចាំថ្ងៃ និងតម្រូវការផលិតផលបំប៉នសុខភាព ឬអាហារបំប៉នសុខភាពដែលចាំបាច់ត្រូវប្រើប្រាស់បន្ថែម។

ក្នុងករណីបងប្អូនប្រជាពលរដ្ឋ ត្រូវការព័ត៌មានបន្ថែមពីនាយកដ្ឋានឱសថ ចំណីអាហារ បរិក្ខារពេទ្យ និងគ្រឿងសំអាងនៃក្រសួងសុខាភិបាល សូមទំនាក់ទំនង តាមរយៈទូរស័ព្ទលេខ៖ ០១២ ៣៥៥ ១៦១, ០១១ ៥៧៤ ៧៨៧, ០១២ ៩៨៣ ៣៣៤, ០១២ ៨៩២ ០២២, ០១៧ ៦០៦ ៦៧០, ០១៧ ៨៦៦ ៧៦០។